អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិក បន្តកើនឡើងគិតត្រឹមរយៈពេលពីរខែដំបូង ឆ្នាំ២០២១
- រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលឡាវ ឯកភាពជំរុញភាពជាដៃគូពាណិជ្ជកម្មទ្វេភាគី ដើម្បីបន្តទំនាក់ទំនងលើវិស័យពាណិជ្ជកម្ម
- ការប្រៀបធៀបការប្រមូលចំណូលរដ្ឋ ក្នុងខែមករា ឆ្នាំ២០២១ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន
- អាជីវកម្មលក្ខណៈគ្រួសារនៅប្រទេសវៀតណាម មានសុទិដ្ឋិនិយមចំពោះកំណើនអាជីវកម្មរបស់ខ្លួននាពេលអនាគត
- ប្រទេសសិង្ហបុរី ក្លាយជាប្រទេសដំបូងគេក្នុងការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀង RCEP
- ឱនភាពថវិកាសហរដ្ឋអាមេរិក លោតដល់កំណត់ត្រាខ្ពស់បំផុតចំនួន ១,៧ទ្រីលានដុល្លារអាមេរិក
- មន្ត្រី IMF ព្រមានថាកង្វះវ៉ាក់សាំងនៅក្នុងប្រទេសដែលមានចំណូលទាប នឹងធ្វើឱ្យរងគ្រោះទាំងអស់គ្នា


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី		អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គីម សុចិត្រា		អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី		ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ		អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

ចងក្រង និងបូកសរុបដោយ

- ស៊ិន សុភារ៉ា		អនុប្រធានការិយាល័យវិភាគគោលនយោបាយសាធារណៈ

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិក បន្តកើនឡើង គិតត្រឹមរយៈពេលពីរខែដំបូង ឆ្នាំ២០២១



*ប្រភព៖ Khmer Times ២០២១*

ការនាំចេញរបស់កម្ពុជាទៅកាន់សហរដ្ឋអាមេរិក ដែលជាប្រទេសមានសេដ្ឋកិច្ចធំជាងគេនៅលើពិភពលោក បានបន្តកើនឡើង គិតត្រឹមរយៈពេលពីរខែដំបូងនៃឆ្នាំ ២០២១។ យោងតាមទិន្នន័យស្ថិតិពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក បានបង្ហាញថា៖ ចាប់ពីខែមករា ដល់ខែកុម្ភៈ ឆ្នាំ២០២១, ការនាំចេញទំនិញរបស់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិកសម្រេចបាន១,១២ប៊ីលានដុល្លារអាមេរិកកើនឡើង ៣,៣% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ខណៈការនាំចូលទំនិញពីសហរដ្ឋអាមេរិក បានកើនឡើងចំនួន ២៦% ដែលកើនដល់ ៦៧លានដុល្លារអាមេរិក។

ផលិតផលសំខាន់ៗសម្រាប់នាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិករួមមាន៖ ផលិតផលសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ និងកង់។ ចំណែកឯ ផលិតផលសំខាន់ៗសម្រាប់នាំចូលមកកម្ពុជាពីសហរដ្ឋអាមេរិកវិញ មានដូចជា៖ យានយន្ត ចំណីសត្វ និងគ្រឿងម៉ាស៊ីន។

សរុបទំហំពាណិជ្ជកម្មទ្វេភាគីនៃប្រទេសទាំងពីរក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ ២០២១ មានចំនួន ១,១៨ប៊ីលានដុល្លារអាមេរិក កើនឡើង ៤,៤%។

ដោយឡែក, បើយោងតាមរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្ហាញថា៖ ការនាំចេញដ៏ខ្លាំងក្លារបស់កម្ពុជាទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០២០ ត្រូវបានគាំទ្រដោយការនាំចេញផលិតផលមិនមែនសម្លៀកបំពាក់ ដូចជា៖ កង់ គ្រឿងសង្ហារឹម និងគ្រឿងអេឡិចត្រូនិច។

ជារួម ទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរ សម្រេចបានកម្រិតខ្ពស់បំផុតមិនធ្លាប់មានពីមុនមកដល់ទៅ៦,៩២ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២០ គឺកើនឡើង ១៧,៨% ធៀបនឹងឆ្នាំ២០១៩ ដែលក្នុងនោះ

ការនាំចេញពីកម្ពុជា មានតម្លៃ ៦,៥៨ប៊ីលានដុល្លារអាមេរិក ឬកើនឡើង ២២,៨%។ *ដោយ សេន ចន្ទី*

*ប្រភព៖ [គេហទំព័រសារព័ត៌មាន Khmer Times](#) ចុះផ្សាយថ្ងៃទី១០ ខែមេសា ឆ្នាំ២០២១*

## រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលឡាវ ឯកភាពជំរុញភាពជាដៃគូពាណិជ្ជកម្មទ្វេភាគី ដើម្បីបន្តទំនាក់ទំនងលើវិស័យពាណិជ្ជកម្ម




*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២១, រូបភាព៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*

យោងតាមសេចក្តីប្រកាសព័ត៌មាននៃជំនួបសន្ទនារវាងប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងឡាវ តាមរយៈប្រព័ន្ធអ៊ិនធឺណេត បានឱ្យដឹងថា៖ រាជរដ្ឋាភិបាលកម្ពុជា និងឡាវ បានធ្វើការសន្យាពាក់ព័ន្ធនឹងការជំរុញទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគីឱ្យមានទំហំកាន់តែធំបន្ថែមទៀត។ ខណៈទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរ បានកើនឡើងប្រមាណ ៩៤០% នៅឆ្នាំ២០២០។

ឆ្លៀតក្នុងឱកាសនៃជំនួបសន្ទនានេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានសម្តែងការសាទរយ៉ាងខ្លាំងចំពោះ លោក ផនខាំ វិផាវ៉ាន់ ដែលទើបត្រូវបានបោះឆ្នោតជ្រើសតាំងជានាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលនេះអាចជាក្តីសង្ឃឹមមួយក្នុងការបង្កើនទំនាក់ទំនងផ្នែកពាណិជ្ជកម្មរវាងកម្ពុជា និងឡាវ ឱ្យមានសន្ទុះខ្លាំងបន្ថែមទៀត។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ បានបញ្ជាក់ថា៖ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងប្រទេសឡាវ បានស្ទុះឡើងពី ១០លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ ដល់ ១០៤លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២០។ ស្របពេលជាមួយគ្នានេះ ថ្នាក់ដឹកនាំទាំងពីរក៏បានបន្តឯកភាពគ្នាជំរុញឱ្យមានកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្មផងដែរ តាមរយៈការពន្លឿនការចរចាលើ «កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា» ។

បើយោងតាមអ្នកនាំពាក្យក្រសួងពាណិជ្ជកម្ម បានលើកឡើងថា៖ ប្រទេសទាំងពីរ នៅមានឱកាសច្រើនក្នុងការបង្កើនការលើកកម្ពស់ពាណិជ្ជកម្ម និងការវិនិយោគរួមគ្នា។ សម្រាប់មូលហេតុដែលធ្វើឱ្យទំហំពាណិជ្ជកម្មទ្វេភាគីមានទំហំតូចកន្លងមក គឺដោយសារតែប្រទេសទាំងពីរមានមូលដ្ឋានផលិតកម្មស្ទើរតែដូចគ្នា។ ទោះជាយ៉ាងណាក៏ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ បានធ្វើការប្តេជ្ញាចិត្តដ៏រឹងមាំលើសកម្មភាពពាណិជ្ជកម្មមួយចំនួនរួមគ្នា និងផ្លាស់ប្តូរដំណើរទស្សនកិច្ចពាណិជ្ជកម្មរបស់ពាណិជ្ជករ

ដើម្បីរៀនសូត្រពីគ្នាទៅវិញទៅមកលើអ្វីដែលប្រទេសឡាវ ត្រូវការ និងអ្វីដែលប្រទេសកម្ពុជាត្រូវការ ដែលនេះនឹងធ្វើឱ្យប្រទេសទាំងពីរអាចមើលឃើញឱកាសណាមួយ ឬអាចសហប្រតិបត្តិការ ដើម្បីបង្កើនទាំងពាណិជ្ជកម្ម និងការវិនិយោគ។

ក្នុងនោះដែរនៅឆ្នាំ២០០៨ ធនាគារអេស៊ីលីដាភីអិលស៊ី ដែលមានមូលដ្ឋាននៅប្រទេសកម្ពុជា បានចូលទៅបណ្តាក់ទុនលើវិស័យធនាគារនៅប្រទេសឡាវ ដោយប្រើឈ្មោះ «អេស៊ីលីដា ឡាវ»។ *ដោយ សេន ចន្ទី*

*ប្រភព៖ គេហទំព័រសារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះផ្សាយថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១*

## តារាងប្រចាំសប្តាហ៍៖ ការប្រៀបធៀបការប្រមូលចំណូលរដ្ឋក្នុងខែមករា ឆ្នាំ២០២១ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន

យោងតាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្ហាញថាៈការអនុវត្តលើការប្រមូលចំណូលក្នុងស្រុកសរុបថ្នាក់ជាតិ ក្នុងខែមករា ឆ្នាំ២០២១ មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ប្រមាណ១៧% បើធៀបរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។

ជាក់ស្តែងនៅក្នុងខែមករា ឆ្នាំ២០២១ ចំណូលក្នុងប្រទេសសរុបថ្នាក់ជាតិអនុវត្តបាន៧,០៤%នៃច្បាប់ហិរញ្ញវត្ថុ ឬស្មើនឹង ១ ៤០២ប៊ីលានរៀល ដែលធ្លាក់ចុះជិត១៧% ធៀបនឹងខែមករា ឆ្នាំ២០២០។ ក្នុងនោះដែរ ចំណូលសារពើពន្ធ មានចំនួន ១ ៣៦៣ប៊ីលានរៀល ធ្លាក់ចុះ៨% ដែលការធ្លាក់ចុះនេះអាចជាកត្តាមួយដែលបណ្តាលមកពីការធ្លាក់ចុះនូវប្រភពចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស។ ចំណែកឯ ចំណូលមិនមែនសារពើពន្ធ មានចំនួន ៣៩ប៊ីលានរៀល គឺធ្លាក់ចុះយ៉ាងខ្លាំងជាង ៨០% ដែលជាពិសេសមានការថមថយលើការប្រមូលផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវាកម្មផ្សេងៗ។ ដោយឡែក ចំណូលមូលធន ពុំបានរួមចំណែកទេ ទាំងនៅក្នុងខែមករា ឆ្នាំ២០២០ និង ២០២១។

ជារួម ការធ្លាក់ចុះនូវចំណូលថវិកាជាតិនេះ ត្រូវបានមើលឃើញដោយសារការថមថយសកម្មភាពសេដ្ឋកិច្ច ក្នុងបរិការណ៍ ការរីករាលដាលនៃជំងឺកូវីដ-១៩ និងការអនុវត្តវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ក៏ដូចជាការលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទ សម្រាប់វិស័យទេសចរណ៍ និងពន្ធអប្បបរមាសម្រាប់វិស័យអាកាសចរណ៍ផងដែរ។ *ដោយ ឈន ហាំ*

| ចំណូល(ប៊ីលានរៀល) | អនុវត្តន៍ | | ច្បាប់ | | ធៀបនឹងច្បាប់ | | កំណើន(%) |
|---|---|---|---|---|---|---|---|
| | Jan-20 | Jan-21 | 2020 | 2021 | Jan-20 | Jan-21 | Jan(2020-21) |
| ចំណូលក្នុងស្រុកសរុបថ្នាក់ជាតិ | 1,686 | 1,402 | 24,093 | 19,927 | 7.00% | 7.04% | -16.82% |
| ចំណូលសារពើពន្ធ | 1,485 | 1,363 | 21,091 | 17,520 | 7.04% | 7.78% | -8.23% |
| ចំណូលមិនមែនសារពើពន្ធ | 201 | 39 | 2,808 | 2,186 | 7.15% | 1.80% | -80.36% |
| ចំណូលមូលធន | 0 | 0 | 193 | 221 | 0.0% | 0.0% | 0.00% |

*ប្រភព៖ ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ ការអនុវត្តថវិការដ្ឋ ខែមករា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### អាជីវកម្មលក្ខណៈគ្រួសារនៅប្រទេសវៀតណាម មានសុទិដ្ឋិនិយមចំពោះកំណើនអាជីវកម្មរបស់ខ្លួននាពេលអនាគត



*ប្រភព៖ Vietnam Plus ២០២១, រូបភាព៖ Vietnam News Agency*

យោងតាមការស្ទង់មតិអាជីវកម្មលក្ខណៈគ្រួសារជាសកល លើកទី១០ របស់ក្រុមហ៊ុនផ្តល់សេវាកម្មសវនកម្ម Pricewaterhouse Coopers (PwC) ដែលមានមូលដ្ឋាននៅចក្រភពអង់គ្លេស និងជាលើកដំបូងនៃការស្ទង់មតិរបស់ខ្លួនទៅលើអាជីកម្មលក្ខណៈគ្រួសារនៅប្រទេសវៀតណាម បានបង្ហាញថា អាជីវកម្មលក្ខណៈគ្រួសារវៀតណាមចំនួន ៦៥% រំពឹងថាអាជីវកម្មរបស់ពួកគេនឹងមានកំណើននៅឆ្នាំ២០២១ និងចំនួន៧៥% រំពឹងកំណើននៅឆ្នាំ២០២២។

ជាមួយគ្នានេះដែរ អាជីវកម្មលក្ខណៈគ្រួសារចំនួន ៣៣% រំពឹងថា នឹងសម្រេចបាននូវកំណើនខ្ពស់នៅឆ្នាំ២០២២ ដែលការរំពឹងទុកនេះគឺខ្ពស់ជាងការរំពឹងទុករបស់អាជីវកម្មលក្ខណៈគ្រួសារដែលត្រូវបានស្ទង់មតិទាំងក្នុងតំបន់ និងក្នុងសកលលោក។

អាជីវកម្មលក្ខណៈគ្រួសារចំនួន ៥៥%នឹងផ្តោតលើការណែនាំផលិតផល និងសេវាកម្មថ្មីៗ និងចំនួន៥២% នឹងបង្កើនការប្រើប្រាស់បច្ចេកវិទ្យាថ្មី។

លទ្ធផលនៃការស្ទង់មតិបានបង្ហាញថា ក្នុងរយៈពេល ៥ឆ្នាំខាងមុខ អាជីវកម្មលក្ខណៈគ្រួសារវៀតណាម នឹងផ្លាស់ប្តូរឆ្ពោះទៅរកការចូលរួមពីអ្នកខាងក្រៅបន្ថែមទៀត ជាមួយនឹងកំណើនពី ១២% ទៅ ៦០% ដែលមានន័យថា ប្រភេទអាជីវកម្មទាំងនេះ នឹងផ្លាស់ប្តូរពីអាជីវកម្មដែលគ្រប់គ្រងដោយម្ចាស់ ឬគ្រួសារ ទៅជាអាជីវកម្មគ្រួសារដែលគ្រប់គ្រងដោយអ្នកខាងក្រៅ ឬអាជីវកម្មដែលប្រតិបត្តិការដោយអ្នកខាងក្រៅ។

សូមបញ្ជាក់ដែរថា ការស្ទង់មតិនេះ ត្រូវបានធ្វើឡើងតាមរយៈការស្ទង់មតិម្ចាស់អាជីវកម្មចំនួន ២ ៨០១នាក់ នៅក្នុងប្រទេស និងដែនដីចំនួន ៨៧។ ក្នុងចំណោមម្ចាស់អាជីវកម្មទាំងអស់នោះ មានម្ចាស់អាជីវកម្មចំនួន ៣៣នាក់ មកពីប្រទេសវៀតណាម តំណាងឱ្យអាជីវកម្ម និងឧស្សាហកម្មចម្រុះ ហើយគម្រូប្រតិបត្តិការបច្ចុប្បន្នផ្តោតលើអាជីវកម្មដែលគ្រប់គ្រងជាលក្ខណៈគ្រួសារចំនួន៥២% និងអាជីវកម្មដែលគ្រប់គ្រងដោយម្ចាស់ផ្ទាល់ចំនួន ៣៦% ។ *ដោយ ស៊ិន សុភាព៌*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Vietnam Plus ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១*

## ប្រទេសសិង្ហបុរី ក្លាយជាប្រទេសដំបូងគេក្នុងការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀង RCEP




*ប្រភព៖ The Jakarta Post ២០២១*

យោងតាមសេចក្តីថ្លែងការណ៍របស់ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មនៃប្រទេសសិង្ហបុរី បានឱ្យដឹងថា ប្រទេសសិង្ហបុរី បានក្លាយជាប្រទេសចូលរួមនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីធំបំផុតរបស់ពិភពលោក ដែលបានផ្តល់សច្ចាប័នដំបូងគេដល់កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ (Regional Comprehensive Economic Partnership RCEP)។

ការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀង RCEP នេះ បានបង្ហាញពីការប្តេជ្ញាចិត្តខ្ពស់របស់សិង្ហបុរីក្នុងការពង្រឹងទំនាក់ទំនងពាណិជ្ជកម្ម និងសេដ្ឋកិច្ច ជាមួយបណ្តាប្រទេសជាដៃគូ ដើម្បីជាប្រយោជន៍ដល់អាជីវកម្ម និងប្រជាជនរបស់ខ្លួន។ ទន្ទឹមនឹងនេះ ប្រទេសសិង្ហបុរីសង្ឃឹមថា បណ្តាប្រទេសដែលចូលរួមផ្សេងទៀត នឹងផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀង RCEP នេះ នឹងពន្លឿនការចូលជាធរមាន នេះបើយោងតាមប្រសាសន៍របស់លោក Chan Chun Sing រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មនៃប្រទេសសិង្ហបុរី ដែលមាននៅក្នុងសេចក្តីថ្លែងការណ៍។

សូមបញ្ជាក់ដែរថា កិច្ចព្រមព្រៀង RCEP ត្រូវបានចុះហត្ថលេខាកាលពីខែវិច្ឆិកា ឆ្នាំ២០២០ ដោយប្រទេសចំនួន ១៥ នៅអាស៊ីប៉ាស៊ីហ្វិក ដែលរួមមាន៖ ប្រទេសសមាជិកទាំង ១០ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) និងប្រទេសជប៉ុន ចិន កូរ៉េខាងត្បូង អូស្ត្រាលី និងប្រទេសនូវែលសេឡង់។ កិច្ចព្រមព្រៀង RCEP នឹងអាចចូលជាធរមាន នៅពេលដែលកិច្ចព្រមព្រៀងនេះត្រូវបានផ្តល់សច្ចាប័នដោយប្រទេសសមាជិកអាស៊ាន ចំនួន ៦ និង៣ប្រទេសផ្សេងទៀត។

កិច្ចព្រមព្រៀងនេះ បានបង្កើតឱ្យមានប្លុកពាណិជ្ជកម្មដ៏ធំបំផុតមួយនៅលើពិភពលោក ដែលមានប្រមាណ ៣០% នៃផលិតផលក្នុងស្រុកសរុបសកល និងប្រហែលមួយភាគបីនៃចំនួនប្រជាជនពិភពលោក៕

*ដោយ សុិន សុភារ៉*

*ប្រភព៖ គេហទំព័រសារព័ត៌មាន The Jakarta Post ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### ឱនភាពថវិកាសហរដ្ឋអាមេរិក លោតដល់កំណត់ត្រាខ្ពស់បំផុតចំនួន ១,៧ទ្រីលានដុល្លារអាមេរិក



*ប្រភព៖ the Philadelphia Financial Center.២០២១, រូបភាព៖ Jeff Fusco | Getty Images*

ឱនភាពថវិការបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក បានកើនឡើងដល់កម្រិតខ្ពស់បំផុតចំនួន ១,៧ទ្រីលានដុល្លារអាមេរិក ក្នុងរយៈពេល៦ខែដំបូង ពោលគឺជិតទ្វេដងនៃកំណត់ត្រាមុន ខណៈដែលជុំមួយទៀតនៃមូលប្បទានបត្រគាំទ្រផ្នែកសេដ្ឋកិច្ច បានបន្ថែមទឹកប្រាក់រាប់ពាន់លានដុល្លារទៅលើការចំណាយកាលពីខែមុន។

យោងតាមរបាយការណ៍ប្រចាំខែរបស់ក្រសួងរតនាគារសហរដ្ឋអាមេរិក បានបង្ហាញថា ថវិការបស់ខ្លួនមានឱនភាពនៅក្នុង៦ខែដំបូង នៃថវិកាឆ្នាំ២០២១ ចំនួន ១,៧ទ្រីលានដុល្លារអាមេរិក គិតចាប់ពីខែតុលា ឆ្នាំ ២០២០ ដល់ ខែមីនា ឆ្នាំ២០២១ ពោលគឺកើនឡើងពីឱនភាព ៧៤៣,៥ប៊ីលានដុល្លារអាមេរិក ក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ឱនភាពនេះ បានកើនឡើងខ្ពស់ជាងរាប់ពាន់លានដុល្លារ ដោយសារសភាបានអនុម័តសម្រាប់គាំទ្រដល់កញ្ចប់សង្គ្រោះសេដ្ឋកិច្ចជាបន្តបន្ទាប់ចាប់តាំងពីការផ្ទុះឡើងជំងឺរាតត្បាតកូវីដ-១៩ នៅដើមខែមីនា ឆ្នាំ២០២០។

ប្រធានាធិបតីអាមេរិក លោក Joe Biden បានជំរុញថវិកាជុំចុងក្រោយ តាមរយៈសភាកាលពីខែមុន ក្នុងទឹកប្រាក់ចំនួន ១,៩ទ្រីលានដុល្លារអាមេរិក ដែលកញ្ចប់ថវិកានេះ រួមបញ្ចូលទាំងការផ្ដល់ជូននូវទឹកប្រាក់ជាលក្ខណៈបុគ្គលរហូតដល់ ១ ៤០០ដុល្លារអាមេរិក ហើយរដ្ឋបាលបានប្រញាប់ធ្វើការទូទាត់ប្រាក់ទាំងនោះភ្លាមៗ នៅពេលដែលលោក Biden ចុះហត្ថលេខាលើវិធានការនេះឲ្យក្លាយជាច្បាប់។ សេចក្ដីថ្លែងការណ៍របស់ក្រសួងរតនាគារ បានបង្ហាញថា ចំណាយក្នុងខែមីនាមានចំនួនសរុប ៣៣៩ប៊ីលានដុល្លារអាមេរិក។

របាយការណ៍ថវិកា បានបង្ហាញថា ឱនភាពសម្រាប់ខែមីនាឆ្នាំ២០២១ មានចំនួនសរុប ៦៥៩,៦ប៊ីលានដុល្លារអាមេរិកដែលជាឱនភាពប្រចាំខែខ្ពស់បំផុតទីបី។ សម្រាប់រយៈពេល ៦ខែ ឱនភាពសរុបមានចំនួន ១,៧ទ្រីលានដុល្លារអាមេរិក កើនលើសកំណត់ត្រាចាស់នៃឱនភាព ៨២៩ប៊ីលានដុល្លារអាមេរិក សម្រាប់រយៈពេល ៦ខែ គិតត្រឹមខែមីនា ឆ្នាំ២០១១ ដែលជារយៈពេលមួយដែលរដ្ឋាភិបាលបានដោះស្រាយផលប៉ះពាល់អវិជ្ជមាននៃវិបត្តិសេដ្ឋកិច្ច ដែលបណ្ដាលមកពីវិបត្តិហិរញ្ញវត្ថុ ឆ្នាំ២០០៨ ។

ឱនភាពថវិកាឆ្នាំមុន ដែលបញ្ចប់ត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ មានចំនួនសរុប ៣,១ទ្រីលានដុល្លារអាមេរិក។ ការិយាល័យថវិកាសភាអាមេរិក បានប៉ាន់ស្មានថា ឱនភាពថវិកាសម្រាប់ឆ្នាំ២០២១ មានចំនួនសរុប

២,៣ទ្រីលានដុល្លារអាមេរិក ប៉ុន្តែ ការប៉ាន់ស្មាននោះ មិនបានរាប់បញ្ចូលចំណាយនៃផែនការជួយសង្គ្រោះ ចំនួន ១,៩ទ្រីលានដុល្លារអាមេរិក ឬផលប៉ះពាល់នៃ សំណើលើកកសាងហេដ្ឋារចនាសម្ព័ន្ធ "Build Back Better" របស់លោកប្រធានាធិបតី ដែលសភាកំពុង ពិចារណានាពេលនេះទេ៕ *ដោយ វត្តា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNBC ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ ២០២១*

## មន្ត្រី IMF ព្រមានថាកង្វះវ៉ាក់សាំងនៅក្នុងប្រទេសដែលមានចំណូលទាប នឹងធ្វើឱ្យរងគ្រោះទាំងអស់គ្នា

មន្ត្រីមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានលើកឡើង អំពីសារៈសំខាន់សម្រាប់ប្រទេសដែលមានប្រាក់ចំណូល ទាប និងប្រទេសដែលមានទីផ្សារកំពុងរីកលូតលាស់ ក្នុង ការមានលទ្ធភាពទទួលបានវ៉ាក់សាំងបន្ថែមទៀត និង ព្រមានថាបើគ្មានការពង្រីកការចាក់វ៉ាក់សាំងទេ ជំងឺ រាតត្បាតកូវីដ-១៩នឹងមិនបញ្ចប់ដែលអាចនឹងបណ្តាល ឱ្យរងគ្រោះទាំងអស់គ្នា។

នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រី Petya Koeva Brooks អនុប្រធាននាយកដ្ឋានស្រាវជ្រាវរបស់ IMF បានប្រាប់ សារព័ត៌មាន Xinhua ថា មានភាពមិនប្រាកដប្រជា ជុំវិញការព្យាករណ៍សេដ្ឋកិច្ចពិភពលោកហើយប្រភព សំខាន់នៃភាពមិនច្បាស់លាស់នោះ គឺជាគន្លងនៃជំងឺ រាតត្បាត និងដំណើរការនៃការចាក់វ៉ាក់សាំងការពារ។

ជាមួយគ្នានេះ ក្រៅពីវីរុស កូវីដ-១៩ លោកស្រី បាន លើកឡើងពីហានិភ័យផ្សេងៗទៀត ចំពោះការងើបឡើង វិញនៃសេដ្ឋកិច្ចពិភពលោកដូចជា៖ ភាពតានតឹងផ្នែក ពាណិជ្ជកម្ម និងបច្ចេកវិទ្យា។ លោកស្រី បានគិតថា ឥឡូវជាពេលដែលសេដ្ឋកិច្ចពិភពលោក គួរតែទទួល បានអត្ថប្រយោជន៍ពីប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិដែល បើកចំហរ ស្ថិរភាព តម្លាភាព និងផ្អែកលើច្បាប់។

យោងតាមរបាយការណ៍ចក្ខុវិស័យសេដ្ឋកិច្ចពិភពលោក (World Economic Outlooks) ចុងក្រោយបង្អស់ ដែល បានចេញផ្សាយកាលពីសប្តាហ៍មុន បានព្យាករណ៍ថា សេដ្ឋកិច្ចពិភពលោកនឹងមានកំណើន ៦% ក្នុងឆ្នាំ ២០២១ ពោលគឺកើនឡើង ០,៥ពិន្ទុភាគរយ លើសការ ព្យាករណ៍នៅក្នុងខែមករា ជាមួយនឹងការរីកចម្រើននៃ ការចាក់វ៉ាក់សាំង នៅក្នុងប្រទេសមួយចំនួន និងការគាំទ្រ ថវិកាបន្ថែមនៅក្នុងប្រទេសសេដ្ឋកិច្ចធំៗ ជាពិសេសនៅ សហរដ្ឋអាមេរិក។ ជាមួយគ្នានេះ នៅក្នុងសេណារីយ៉ូនៃ ការធ្លាក់ចុះ ការពន្យារពេលការចាក់វ៉ាក់សាំង និងផល វិបាកពីជំងឺកូវីដ-១៩ សេដ្ឋកិច្ចពិភពលោក ត្រូវបានគេ រំពឹងថានឹងមានកំណើន ៤,៥% ទាបជាង ១,៥ពិន្ទុ ភាគរយ ពីការព្យាករណ៍មូលដ្ឋាន។

លោកស្រីបានលើកឡើងទៀតថា ពិភពលោកទាំងមូល បានផ្តល់ការគាំទ្រផ្នែកសារពើពន្ធចំនួន ៩% នៃផ.ស.ស. ដែលក្នុងនោះ ប្រទេសមានសេដ្ឋកិច្ចជឿនលឿន មាន ចំនួនលើសពី ១៦% ខណៈ នៅក្នុងប្រទេសដែលមាន ប្រាក់ចំណូលទាប មានចំនួនត្រឹម ១,៧% ដែលនេះគឺ ជាបញ្ហា។

រហូតមកដល់ពេលនេះ ស្ថាប័នពហុភាគីមួយនេះបាន គាំទ្រដល់ប្រទេសចំនួន ៨៦ ដែលមានទឹកប្រាក់ជាង

១១០ប៊ីលានដុល្លារអាមេរិក តាមរយៈវិធីសាស្ត្រផ្សេងៗ ហើយខ្លួនបានគ្រោងស្នើសុំធ្វើការបែងចែកថវិកាអន្តរជាតិជាថ្មីរបស់ IMF (Special Drawing Rights) ចំនួន ៦៥០ប៊ីលានដុល្លារអាមេរិក ដើម្បីជួយបំពេញតម្រូវការរយៈពេលវែងរបស់ពិភពលោក សម្រាប់បំពេញបន្ថែមប្រាក់បម្រុង៕ *ដោយ វត្ថា វង្សខ្មែរ:*

*ប្រភព៖ គេហទំព័រសារព័ត៌មាន XINHUANET ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ សន្ទស្សន៍ឧស្សាហកម្មសេវាកម្ម តុល្យភាពពាណិជ្ជកម្ម និងការវិនិយោគបណ្តុំបំណុលបរទេសនៅប្រទេសជប៉ុន បម្រែបម្រួលភាគហ៊ុនប្រេងឆៅ API និងការដេញថ្លៃបណ្ណរតនាគាររយៈពេល ៦ខែ របស់សហរដ្ឋអាមេរិក ការកំណត់អត្រាការប្រាក់ និងទំនុកចិត្តអាជីវកម្មនៅប្រទេសឥណ្ឌូនេស៊ី និងអត្រាអតិផរណានៅប្រទេសម៉ាឡេស៊ី៕

ខាងក្រោម គឺជាប្រតិទិនដែលនាយកដ្ឋានស្រាវជ្រាវថវិកានឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃចន្ទ ទី១៩ ខែមេសា ឆ្នាំ២០២១

- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសជប៉ុន សម្រាប់ខែមីនា
- ការដេញថ្លៃបណ្ណរតនាគាររយៈពេល ៦ខែ របស់សហរដ្ឋអាមេរិក

ថ្ងៃអង្គារ ទី២០ ខែមេសា ឆ្នាំ២០២១

- ការកំណត់អត្រាការប្រាក់នៅប្រទេសឥណ្ឌូនេស៊ី
- សន្ទស្សន៍ឧស្សាហកម្មសេវាកម្មរបស់ប្រទេសជប៉ុន ធៀបនឹងខែមុន សម្រាប់ខែកុម្ភៈ

ថ្ងៃពុធ ទី២១ ខែមេសា ឆ្នាំ២០២១

- ការបម្រែបម្រួលភាគហ៊ុនប្រេងឆៅ API នៅសហរដ្ឋអាមេរិក សម្រាប់ថ្ងៃទី១៦ ខែមេសា
- ទំនុកចិត្តអាជីវកម្មរបស់ប្រទេសឥណ្ឌូនេស៊ី ប្រចាំត្រីមាសទី១ ឆ្នាំ២០២១

ថ្ងៃព្រហស្បតិ៍ ទី២២ ខែមេសា ឆ្នាំ២០២១

- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសថៃ សម្រាប់ខែមីនា
- ការវិនិយោគបណ្តុំបំណុលបរទេសនៅប្រទេសជប៉ុន សម្រាប់ថ្ងៃទី១៧ ខែមេសា

ថ្ងៃសុក្រ ទី២៣ ខែមេសា ឆ្នាំ២០២១

- អត្រាអតិផរណានៅប្រទេសម៉ាឡេស៊ី ធៀបនឹងឆ្នាំមុន សម្រាប់ខែមីនា
- ការលក់ឡានថ្មីរបស់ប្រទេសថៃ ធៀបនឹងឆ្នាំមុន សម្រាប់ខែមីនា